# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២១៨ សហវ-ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ២៦៥ សហវ.បក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** បង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហៅកាត់ (អកម) ដែលរួមមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរង កសហវ | ប្រធាន |
| ២-លោក **សុខ សារាទុឡ្ល** | ប្រធានលេខាធិការដ្ឋានកំណែទម្រង់ | អនុប្រធាន |
| ៣-លោក **យក់ ម៉ិនណា** | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៤-លោក **សេខ ស្រេខ** | នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៥-លោក **ចែម ទាសនា** | ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ | សមាជិក |
| ៦-លោក **ថៅ សុខមុនី** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នៃអគ្គ-រតនាគាជាតិ | សមាជិក |
| ៧-លោក **អៀម ស៊ុនលី** | អនុប្រធានទី ១ នៃនាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| ៨-លោក **ទង្វ វ៉ាំងទុល** | អនុប្រធានទី ១ នៃនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៩-លោក **ម៉ែន ធីរុទ្ធ** | អនុប្រធានទី ១ នៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | សមាជិក |
| ១០-លោក **ឆាំង ទ៉ាន់ថា** | អនុប្រធានន-រដ្ឋបាល និងគ្រប់គ្រង នៃអគ្គ-គយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១១-លោក **មន្ត ច្រាថ្លា** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា | សមាជិក |
| ១២-លោក **អ៊ិន អេម** | នាយករងវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ២:** អនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការ មានមុខងារ និង ភារកិច្ច ដូចតទៅ:

-ធ្វើជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំអនុវត្តផែនការ កម្មវិធី និង វគ្គបណ្តុះបណ្តាលនានា ដើម្បីកសាងសមត្ថភាពមន្ត្រីរាជការ សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-ដឹកនាំ តាមដានអនុវត្ត និង ណែនាំ ក្នុងការកសាងសមត្ថភាពមន្ត្រីរាជការ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

-ធ្វើជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការកសាងសមត្ថភាពមន្ត្រីរាជការនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនាយកដ្ឋាន/អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង/ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ។

-ធ្វើរបាយការណ៍ និង ជូនយោបល់ដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ថ្នាក់ដឹកនាំក្រសួង ស្តីពីដំណើរការកសាងសមត្ថភាពមន្ត្រីរាជការ ក្នុងការអនុវត្តន៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និង សម្រេច ។

**ប្រការ៣:** អនុគណៈកម្មាធិការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញ និង បំពេញភារកិច្ចតាមការចាត់តាំងរបស់ប្រធាន។ អនុគណៈកម្មាធិការនេះ ត្រូវធ្វើសេចក្តីរាយការណ៍អំពីវត្តមាន និង សកម្មភាពចូលរួមរបស់សមាជិកម្នាក់ៗ ជូនឯកឧត្តមរដ្ឋលេខាធិការ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជ្រាបជាប្រចាំ។

**ប្រការ៤:** អនុគណៈកម្មាធិការនេះមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសជំនាញទៅតាមការចាំបាច់ ។

**ប្រការ៥:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួន ដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃកសហវ
- គ្រប់នាយកដ្ឋានក្រោមឱវាទ កសហវ
- សាមីខ្លួន ដើម្បីអនុវត្ត
- កាលប្បវត្តិ ឯកសារ